ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តក្រចេះ

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តក្រចេះ**

សាលក្រមរដ្ឋប្បវេណី

លេខ: ៦៣ "ឈ"

ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣

សំណុំរឿងរដ្ឋប្បវេណី

លេខ: ៧៤

ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣

**បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣។**

**សាលក្រមប្រកាសជាសាធារណៈ នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣។**

-លោក [redacted]ចៅក្រមសាលាដំបូងខេត្តក្រចេះ។

-លោក [redacted]ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ។

**រវាង** ដើមចោទឈ្មោះ [redacted]**វិចិត្រ** ភេទប្រុស កើតថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៧៩ ជាតិខ្មែរ ទីលំនៅ [redacted]ដែលមានតំណាងដោយអាណត្តិលោកមេធាវី [redacted]

**និង** ចុងចម្លើយឈ្មោះ [redacted]**សុខេន** ភេទស្រី កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៩ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ [redacted]ដែលមានតំណាងដោយអាណត្តិលោកមេធាវី [redacted]។

**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការសម្រេច:**

១.សុំឱ្យដើមចោទ និងចុងចម្លើយផ្តាច់សមគ្គសង្វាស ដែលមានសំបុត្រអាពាហ៍ពិពាហ៍។

២.សម្រេចឲ្យដើមចោទជាអ្នកមានអំណាចមេបាលើកូនទាំង០៣នាក់ កូនទី១.ឈ្មោះ [redacted]សុខុមាលីស ភេទស្រី អាយុ ១៤ឆ្នាំ ដែលមានសំបុត្រកំណើតលេខ: ៨២ (សៀវភៅបញ្ជាក់កំណើតលេខ:០១/២០១០) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ចេញដោយចៅសង្កាត់ក្រចេះ កូនទី២.ឈ្មោះ [redacted]សុភារី ភេទស្រី អាយុ ៥ឆ្នាំ មានសំបុត្រកំណើតលេខ: ២១ (សៀវភៅបញ្ជាក់កំណើតលេខ:០១/២០១៨) ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ ចេញដោយសង្កាត់ក្រចេះ និងកូនទី៣.ឈ្មោះ [redacted]សុផាលីន ភេទស្រី អាយុ ១២ឆ្នាំ មានសំបុត្រកំណើតលេខ: ៨២ (សៀវភៅបញ្ជាក់កំណើតលេខ:០១/២០១០) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០។

៣.សុំបែងចែកទ្រព្យសម្បត្តិរួម នូវអចលនវត្ថុដី/ផ្ទះ ស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ។

**អង្គហេតុ**

**១-អង្គហេតុ:**

-កាលពីអំឡុងឆ្នាំ២០០៤ ដើមចោទឈ្មោះ [redacted]វិចិត្រ បានរៀងអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted]សុខេន និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ: ០៧ សៀវភៅអាពាហ៍ពិពាហ៍លេខ: ០១/២០០៤ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ នៅសង្កាត់អូរឬស្សីត្រឹមត្រូវតាមច្បាប់។ ការរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធបង្កើតបានកូនស្រីចំនួន០៤នាក់ គឺកូនទី១.ឈ្មោះ [redacted]សុខុមាលីស ភេទស្រី អាយុ ១៤ឆ្នាំ, កូនទី២.ឈ្មោះ [redacted]សុភារី ភេទស្រី អាយុ ៥ឆ្នាំ, កូនទី៣.ឈ្មោះ [redacted]សុផាលីន ភេទស្រី អាយុ ១២ឆ្នាំ និងកូនទី៤.ឈ្មោះ [redacted]សុខុមាល័យ ភេទស្រី អាយុ ១៨ឆ្នាំ។ មូលហេតុនៃការប្តឹងសុំលែងលះពីប្រពន្ធឈ្មោះ [redacted]សុខេន ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នាអស់រយៈពេល



Scanned with CamScanner

២.សម្រេចឱ្យចុងចម្លើយជាអ្នកមានអំណាចមេបាលើកូនទាំង០៣(បី)នាក់ កូនទី១.ឈ្មោះ [redacted] សុខុមាលីស ភេទស្រី អាយុ ១៤ឆ្នាំ, កូនទី២.ឈ្មោះ [redacted] សុភារី ភេទស្រី អាយុ ៥ឆ្នាំ និងកូនទី៣.ឈ្មោះ [redacted] សុផាលីន ភេទស្រី អាយុ ១២ឆ្នាំ។

៣.សុំបែងចែកទ្រព្យសម្បត្តិរួមមាន: ខ្ទង់អចលនវត្ថុដែលមានក្បាលដីលេខ: ១០០២០៩០៤-០២០៥ ស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ។

-តំណាងដោយអាណត្តិឱ្យដើមចោទលោកមេធាវី [redacted] បានថ្លែងការណ៍ថា: ខ្ញុំសូមឯកភាពតាមការថ្លែងការណ៍របស់ដើមចោទទាំងស្រុងដោយគ្មានអ្វីបន្ថែមឡើយ។

ខ-លោកមេធាវី [redacted] បានថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្ញុំសុំរក្សាខ្លឹមសារនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ០២ និង៣០ នាទី រសៀល ដូចខាងក្រោម: នាងខ្ញុំបានរៀបការកាលពីអំឡុងឆ្នាំ២០០៤ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ: ០៧ សៀវភៅអាពាហ៍ពិពាហ៍លេខ: ០១/២០០៤ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ នៅសង្កាត់អូរឬស្សី។ ការរស់នៅជាប្ដីប្រពន្ធបានរស់រយៈពេល១៥ឆ្នាំ ហើយបង្កើតបានកូនស្រីចំនួន០៤នាក់ គឺកូនទី១.ឈ្មោះ [redacted] សុខុមាលីស ភេទស្រី អាយុ ១៤ឆ្នាំ ដែលមានសំបុត្រកំណើតលេខ: ៨២ (សៀវភៅបញ្ជាក់កំណើតលេខ:០១/២០១០) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ របស់សង្កាត់ក្រចេះ កូនទី២.ឈ្មោះ [redacted] សុភារី ភេទស្រី អាយុ ៥ឆ្នាំ មានសំបុត្រកំណើតលេខ: ២១ (សៀវភៅបញ្ជាក់កំណើតលេខ: ០១/២០១៩) ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់សង្កាត់ក្រចេះ កូនទី៣.ឈ្មោះ [redacted] សុផាលីន ភេទស្រី អាយុ ១២ឆ្នាំ មានសំបុត្រកំណើតលេខ: ៤៧ (សៀវភៅបញ្ជាក់កំណើតលេខ: ០២/២០១១) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ របស់សង្កាត់ក្រចេះ និងកូនទី៤.ឈ្មោះ [redacted] សុខុមាល័យ ភេទស្រី អាយុ ១៨ឆ្នាំ មានសំបុត្រកំណើតលេខ: ៨១ សៀវភៅបញ្ជាក់កំណើតលេខ: ០១/២០១០ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ របស់សង្កាត់ក្រចេះ។ នាងខ្ញុំឯកភាពក្នុងការលែងជាមួយដើមចោទឈ្មោះ [redacted] វិចិត្រ ហើយនាងខ្ញុំមិនឯកភាពប្រគល់អំណាចមេបាលើកូនស្រីចំនួន០៣ គឺកូនទី១.ឈ្មោះ [redacted] សុខុមាលីស ភេទស្រី អាយុ ១៤ឆ្នាំ កូនទី២.ឈ្មោះ [redacted] សុភារី ភេទស្រី អាយុ ៥ឆ្នាំ និងកូនទី៣.ឈ្មោះ [redacted] សុផាលីន ភេទស្រី អាយុ ១២ឆ្នាំ ឱ្យទៅដើមចោទឈ្មោះ [redacted] វិចិត្រ នោះទេ។ នាងខ្ញុំសូមជាអ្នកមានអំណាចមេបាលើកូនចំនួនបីនាក់គឺ កូនទី១.ឈ្មោះ [redacted] សុខុមាលីស ភេទស្រី អាយុ ១៤ឆ្នាំ កូនទី២.ឈ្មោះ [redacted] សុភារី ភេទស្រី អាយុ ៥ឆ្នាំ និងកូនទី៣.ឈ្មោះ [redacted] សុផាលីន ភេទស្រី អាយុ ១២ឆ្នាំ។ រីឯ ទ្រព្យរួមគឺគ្មានទេ។ ចំណែកឯកផ្ទះនិងដីដែលមានទីតាំងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ គឺជាទ្រព្យសម្បត្តិដោយឡែក ពីព្រោះទ្រព្យនេះជាទ្រព្យសម្បត្តិរបស់ឪពុកម្ដាយរបស់នាងខ្ញុំដែលបានប្រគល់ឱ្យមកនាងខ្ញុំតាំងពីយូរមកហើយ។ ចំពោះមូលហេតុដែលនាំឱ្យមានឈ្មោះ [redacted] វិចិត្រ នៅក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ១០០២០៩០៤-០២០៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ដោយសារខាងធនាគារតម្រូវឱ្យដាក់ឈ្មោះទាំងពីរនាក់ប្ដីប្រពន្ធ ទើបធនាគារគេឱ្យខ្ចីប្រាក់។ ចំណែកឯបំណុលរួម គឺមានចំនួន៨០,០០០(ប៉ែតសិបម៉ឺន)ដុល្លារអាមេរិក ដោយចែកគ្នាបានម្នាក់ចំនួន៤០,០០០(បួនម៉ឺន)ដុល្លារ



Scanned with
CamScanner

ពិតប្រាកដក្នុងការលែងលះ ហើយស្ថានភាពរបស់គូភាគីក្នុងការរស់នៅជាប្តីប្រពន្ធ គឺមិនអាចរក្សាទំនាក់ទំនងអាពាហ៍ពិពាហ៍ និងមានស្ថានភាពធ្ងន់ធ្ងរដែលគ្មានសង្ឃឹមថានឹងអាចស្តារឡើងវិញបាន។ ហេតុនេះការប្តឹងសុំលែងលះរបស់ដើមចោទ គឺមានមូលហេតុត្រឹមត្រូវតាមមាត្រា៩៧៨ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។ គប្បីតុលាការធ្វើការពិនិត្យ និងពិចារណា ដោយផ្អែកនៅលើឆន្ទៈរបស់គូភាគីក៏ដូចជាមូលហេតុដែលនាំឱ្យចំណងអាពាហ៍ពិពាហ៍នេះមិនអាចធ្វើបដិទានវិញបាន។

៣-គូភាគីបានថ្លែងការណ៍ថា: ការរស់នៅជាប្តីប្រពន្ធបង្កើតបានកូនចំនួនបួននាក់ គឺកូនទី១.ឈ្មោះ [redacted] សុខុមាលីស ភេទស្រី អាយុ ១៤ឆ្នាំ, កូនទី២.ឈ្មោះ [redacted] សុភារី ភេទស្រី អាយុ ៥ឆ្នាំ និងកូនទី៣.ឈ្មោះ [redacted]សុដាលីន ភេទស្រី អាយុ ១២ឆ្នាំ ដោយដើមចោទយល់ព្រមប្រគល់អ្នកមានអំណាចមេបាលើកូនចំនួនបីនាក់ ឱ្យចុងចម្លើយ ហើយចុងចម្លើយមិនទាមទារសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូននោះទេ ប៉ុន្តែដើមចោទថានឹងជួយសោហ៊ុយចាំបាច់ក្នុងការចិញ្ចឹមកូនតាមលទ្ធភាព។ ដូច្នេះ ការថ្លែងការណ៍នេះមានភាពស៊ីសង្វាក់ជាមួយសំបុត្របញ្ជាក់កំណើតលេខ: ៨២ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ របស់ឈ្មោះ[redacted]សុខុមាលីស, សំបុត្របញ្ជាក់កំណើតលេខ: ២១ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ[redacted]សុភារី និងសំបុត្របញ្ជាក់កំណើតលេខ: ៤៧ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ[redacted]សុដាលីន បញ្ជាក់ថា: កូនទី១.ឈ្មោះ [redacted] សុខុមាលីស ភេទស្រី អាយុ ១៤ឆ្នាំ, កូនទី២.ឈ្មោះ [redacted]ុភារី ភេទស្រី អាយុ ៥ឆ្នាំ និងកូនទី៣.ឈ្មោះ[redacted]សុដាលីន ភេទស្រី អាយុ ១២ឆ្នាំ ពិតជាកូនរបស់គូភាគីប្រាកដមែន។ គប្បី តុលាការសម្រេចការកំណត់យកអ្នកមានអំណាចមេបា និងសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនតាមការព្រមព្រៀងរបស់ភាគី។

៤-ដើមចោទបានថ្លែងការណ៍ថា: ចំពោះអចលនវត្ថុដី/ផ្ទះមួយកន្លែងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ១០០២០៩០៤-០២០៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គឺជាទ្រព្យរួម ប៉ុន្តែចុងចម្លើយបានថ្លែងការណ៍ថា: ជាទ្រព្យដោយឡែក ពីព្រោះទ្រព្យនេះជាទ្រព្យសម្បត្តិរបស់ឪពុកម្តាយរបស់ខ្លួនដែលបានប្រគល់ឱ្យមកខ្លួនតាំងពីយូរមកហើយ។ ហើយមូលហេតុដែលនាំឱ្យមានឈ្មោះដើមចោទនៅក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ១០០២០៩០៤-០២០៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ដោយសារខាងធនាគារតម្រូវឱ្យដាក់ឈ្មោះទាំងពីរនាក់ប្តីប្រពន្ធ ទើបធនាគារគេឱ្យខ្ចីប្រាក់។ ប៉ុន្តែបើផ្អែកតាមសំបុត្រអាពាហ៍ពិពាហ៍លេខ: ០៧ សៀវភៅអាពាហ៍ពិពាហ៍លេខ: ០១/២០០៤ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ របស់ឃុំអូរឫស្សី បញ្ជាក់ថា: អចលនវត្ថុដី/ផ្ទះមួយកន្លែងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ១០០២០៩០៤-០២០៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គឺជាទ្រព្យដែលកើតឡើងនៅក្នុងចំណងអាពាហ៍ពិពាហ៍។ ដែលចំណុចនេះ គប្បីតុលាការពិនិត្យ និងពិចារណាបែងចែកទ្រព្យជាពីរចំណែកស្មើគ្នាតាមមាត្រា៩៨០ កថាខណ្ឌទី២ ចំណុច ខ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំណែកឯទ្រព្យដោយឡែក គឺគ្មានទេ ប៉ុន្តែចំពោះបំណុលរួមគឺមានចំនួន៨០,០០០(ប្រាំបីម៉ឺន)ដុល្លារអាមេ



Scanned with CamScanner